# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧ នៅវេលាម៉ោង ៨:៣០ នាទីព្រឹក នៅទីស្តីការនាយករដ្ឋមន្ត្រី (វិមានសន្តិភាព) មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពិភាក្សាអំពីរបៀបវារៈដ៏សំខាន់ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ។

ជាលទ្ធផល អង្គគណៈរដ្ឋមន្ត្រី បានអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ដើម្បីរាជរដ្ឋាភិបាលអាចបញ្ជូនសេចក្តីព្រាងច្បាប់នេះដល់រដ្ឋសភា នៅក្នុងសប្តាហ៍ទី ១ នៃខែ វិច្ឆិកា ឆ្នាំ ២០១៧ តាមការកំណត់នៃមាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១៨ នេះ ដូចមានភ្ជាប់មកជាមួយ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ខ្លឹមសារសង្ខេបប្រតិបត្តិ
# ស្តីពី
# សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០១៨

## ១- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០១៨

តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៨ នឹងអាចបន្តសម្រេចបានប្រមាណ ៦,៩% ដូចឆ្នាំ ២០១៧ ដែលធ្វើឱ្យ ផសស តាមថ្លៃបច្ចុប្បន្នកើនឡើងដល់ **៩៩ ១១៦ ០៤១ លានរៀល** ប្រមាណជា ២៤ ៥៥២ លានដុល្លារអាមេរិក ខណៈដែល ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៥៦៨ ដុល្លារអាមេរិក។ កំណើននេះត្រូវបានទ្រទ្រង់ដោយៈ (**ទី១**)-កំណើននៃវិស័យឧស្សាហកម្ម ប្រមាណ ៨,៦% ដែលគាំទ្រដោយអនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ជាពិសេសលើផលិតកម្ម គ្រឿងបង្គុំអេឡិចត្រូនិច ម្ហូបអាហារ និងភេសជ្ជៈ ដែលជួយបំពេញបន្ថែមឱ្យការថមថយនៃអនុវិស័យ កាត់ដេរ និងអនុវិស័យសំណង់។ ថ្វីត្បិតតែអនុវិស័យសំណង់មានកំណើនថមថយបន្តិច ប៉ុន្តែកំណើននេះ នៅតែខ្ពស់ដោយសារសំណង់ប្រភេទពាណិជ្ជកម្ម និងការងាកទៅរកសំណង់លំនៅឋានតម្លៃសមរម្យ ចំណែកឯ ការបន្តថមថយនៃអនុវិស័យកាត់ដេរ គឺបណ្តាលមកពីការកើនឡើងលឿននៃប្រាក់ឈ្នួលអប្បបរមាដែលធ្វើឱ្យ ប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជា និងភាពស្ទាក់ស្ទើរនៃការបញ្ជាទិញ (**ទី២**)-វិស័យសេវាកម្ម បន្តកំណើនប្រមាណ ៧,៦% ដែលគាំទ្រដោយកំណើនខ្ពស់នៃអនុវិស័យលក់ដុំ-រាយ អនុវិស័យដឹកជញ្ជូន និងទូរគមនាគមន៍ ព្រមទាំងអនុវិស័យសេវាកម្មផ្សេងៗ តាមរយៈការកើនឡើងការប្រើប្រាស់ក្នុងស្រុក ដោយសារការកើនឡើងប្រាក់ឈ្នួលអប្បបរមា និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ ស្របនឹងការបន្ត គោលនយោបាយវិត្ថារកម្មរបស់រាជរដ្ឋាភិបាលដែលជួយជំរុញដល់សកម្មភាពសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ អនុវិស័យអចលនទ្រព្យនៅតែបន្តកំណើនរឹងមាំស្របតាមនិន្នាការនៃអនុវិស័យសំណង់ ខណៈដែល អនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ត្រូវបានរំពឹងថាមានកំណើនថមថយបន្តិច និង (**ទី៣**)-វិស័យ កសិកម្ម អាចសម្រេចបានកំណើនក្នុងរង្វង់ ២,០% ទ្រទ្រង់ដោយអនុវិស័យដំណាំ និងជលផល ដោយសារ ភាពប្រសើរឡើងនៃប្រព័ន្ធស្រោចស្រព និងការរំពឹងទុកលក្ខខណ្ឌអំណោយផលនៃកត្តាអាកាសធាតុ។

**អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ** ត្រូវបានប៉ាន់ស្មានថានឹងមានការកើនឡើងបន្តិចក្នុងអត្រា ៣,៨% ក្នុងឆ្នាំ ២០១៧ និង ៣,៥% ក្នុង ឆ្នាំ ២០១៨ ដោយសារការងើបឡើងវិញជាបណ្តើរៗនៃថ្លៃប្រេង លើទីផ្សារអន្តរជាតិ និងថ្លៃកសិផលមួយចំនួន។ ចំណែកឯ**អត្រាប្តូរប្រាក់រៀល** គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ ៤ ០៣៧ រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៧ និង ២០១៨។ **ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ ក្រៅប្រទេស**ត្រូវបានព្យាករថា អាចនឹងកើនឡើងដល់ ៨,៤% នៃ ផសស នៅឆ្នាំ ២០១៨ ធៀបនឹង ៧,៩%

នៃ ផសស នៅឆ្នាំ ២០១៧ ដោយសារការរំពឹងទុកនៃការថមថយនៃឥណទានដែលបានមកពីប្រភពហិរញ្ញប្បទានឥតសំណង ក្រោមហេតុផលថាកម្ពុជាបានប្រែក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ខណៈដែលឱនភាពពាណិជ្ជកម្មបានធ្លាក់ចុះពី ១៥,៤% នៃ ផសស ក្នុងឆ្នាំ ២០១៧ មកត្រឹម ១៥% នៃ ផសស ក្នុងឆ្នាំ ២០១៨ ដែលឆ្លុះបញ្ចាំងនូវពិពិធកម្មផលិតផលនាំចេញ។ **ទុនបម្រុងអន្តរជាតិ** ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ ៩ ០៥០ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៧ និងព្យាករថានឹងបន្តកើនឡើងដល់ ១០ ៥១៨ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ ២០១៨ ដែលធានាបាននូវការនាំចូលប្រមាណ ៦,៥ ខែ នៅឆ្នាំ ២០១៨។

ជារួម ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចដូចដែលបានកំណត់ខាងលើ យើងអាចនិយាយបានថា កម្ពុជានៅតែអាចបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលខ្លី និង មធ្យមខាងមុខ។ ទោះបីយ៉ាងនេះក្តី, កម្ពុជានឹងត្រូវបន្តប្រឈមនឹងហានិភ័យដែលបណ្តាលមកពីកត្តាខាងក្រៅ និងកត្តាខាងក្នុងមួយចំនួនដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តនូវវិធានការគោលនយោបាយមុតស្រួចមួយចំនួនឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ សំដៅជម្នះ និងដោះស្រាយចំពោះរាល់បញ្ហាប្រឈម និងហានិភ័យនានា ដើម្បីធានារក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង សម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព។

## ២-ក្របខ័ណ្ឌគោលនយោបាយថវិកាឆ្នាំ ២០១៨

ថវិកាឆ្នាំ ២០១៨ ត្រូវបានរៀបចំដើម្បីឆ្លើយតបនឹងគោលនយោបាយសំខាន់ៗដូចខាងក្រោម៖

- បន្តពង្រឹងយ៉ាងម៉ឺងម៉ាត់ និងដាច់ខាតនូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម និងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងភាពសុខដុមរមនាក្នុងសង្គម ក៏ដូចជាភាពសុខក្សេមក្សាន្តរបស់ប្រជាជន
- បន្តធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា និងបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ ដល់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ប្រកបដោយបរិយាប័ន្ន និងចីរភាព ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន និងដើម្បីផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ និងបង្កើនចំណូលថវិកាជាតិផងដែរ
- បន្តធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងឱ្យបាននូវអតិផរណា និងស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ
- បន្តផ្តល់អាទិភាពដល់ការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីសម្រេចឱ្យបាននូវគោលដៅជាង ១ លានរៀលនៅឆ្នាំ ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃ

ការផ្តល់សេវាសាធារណៈ និងបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរ ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (២០១៥-២០១៨) ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

- គាំទ្រដល់ការអនុវត្ត**កម្មវិធីថ្មីៗមួយចំនួនលើវិស័យសង្គមកិច្ច** ក្នុង**ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥** ឱ្យចេញជាលទ្ធផលផ្លែផ្កាបណ្តើរៗ ជាពិសេសពាក់ព័ន្ធការថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ការផ្តល់និងបង្កើនប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលជាស្ត្រីនៅពេលសម្រាលកូន និងសម្រាកលំហែមាតុភាព ការបង្កើនប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព ការផ្តល់ការថែទាំសុខភាពសម្រាប់កម្មករ និងការផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពសម្រាប់កម្មការិនី ស្របពេលជាមួយគ្នានឹងការអនុវត្តគោលនយោបាយជាតិមនុស្សចាស់ឆ្នាំ ២០១៧-២០៣០
- បន្តកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាថែមទៀតក្នុងការប្រមូលចំណូល តាមរយៈការជំរុញអនុវត្តវិធានការនៅក្នុង**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ជាពិសេសគឺរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ ដូចសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ទន្ទឹមនឹងបន្តការកែសម្រួលនីតិវិធី និងសេវាពាក់ព័ន្ធនឹងការបង់ពន្ធឱ្យកាន់តែមានភាពសាមញ្ញ និងកាន់តែងាយស្រួល មានយុត្តិធម៌ និងកាន់តែមានអភិបាលកិច្ចខ្ពស់
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ និងបង្កើនចំណាយវិនិយោគផ្ទាល់ដោយថវិកាជាតិ ដើម្បីបង្កើនឯករាជ្យភាពនៃថវិកា និងកាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការលើកកម្ពស់សេវាសុខាភិបាល និងអាហារូបត្ថម្ភ
- បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ ជាពិសេសផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ទឹកស្អាត សាលារៀន និងមន្ទីរពេទ្យជាដើម ព្រមជាមួយនឹងការផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ជាពិសេសទូរគមនាគមន៍ សម្រាប់កសាងមូលដ្ឋានគ្រឹះក្នុងការឈានទៅអនុវត្តសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា
- បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេសផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រស្រោចស្រព
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និង ជំរុញការកែច្នៃ និងនាំចេញផលិតផលកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម រួមទាំងបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងសកម្មភាពអភិវឌ្ឍន៍វិស័យកសិកម្ម ដែលមានភាពធន់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជា

ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការផ្ទុះជម្ងឺ ដើម្បីបញ្ចៀសការខូចខាតពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅលើការអភិវឌ្ឍសេដ្ឋកិច្ច
- បន្តជំរុញការអនុវត្ត**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥**
- បន្តអនុវត្ត**យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៥-២០១៨** ដើម្បីរក្សាចីរភាពនៃបំណុលសាធារណៈផង ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទានសម្រាប់គាំទ្រដល់កំណើន ផលិតភាព និងភាពប្រកួតប្រជែងរបស់កម្ពុជា ដែលមានទំហំកាន់តែធំ ស្របទៅតាមដំណាក់កាលនៃភាពរីកចម្រើនលូតលាស់របស់សេដ្ឋកិច្ចជាតិ
- គាំទ្រដល់ការអនុវត្តកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ២០១៨-២០២០
- គាំទ្រដល់ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០
- បន្តជានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល ឱ្យមានលក្ខណៈកាន់តែស៊ីជម្រៅ និងទទួលបានលទ្ធផលផ្លែផ្កាជាក់ស្តែងកាន់តែច្រើនថែមទៀត រួមទាំងការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ជាពិសេសការលើកកម្ពស់គុណភាព និងពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ ក៏ដូចជាដើម្បីផ្តល់នូវអត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជនទូទៅ និង
- ធានាភាពជោគជ័យនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី ៤ និងតំណាងរាស្ត្រនីតិកាលទី ៦។

ដើម្បីសម្រេចបាននូវគោលបំណងសំខាន់ៗខាងលើ ថវិកាឆ្នាំ ២០១៨ ត្រូវបានរៀបចំឡើងដោយបន្តប្រកាន់យកគោលការណ៍បច្ចេកទេសសំខាន់ៗ ចំនួន ៧ ដូចខាងក្រោម៖

១. ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល
២. ការកំណត់លំដាប់អាទិភាព
៣. ការយកចិត្តទុកដាក់លើមនុស្ស
៤. ការកំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព
៥. ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត
៦. ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា
៧. ការរក្សាតុល្យភាព និងចីរភាពថវិកា។

## ៣-ក្របខ័ណ្ឌថវិកាឆ្នាំ ២០១៨

ឈរលើគោលការណ៍ខាងលើ ក៏ដូចជាក្នុងក្របខ័ណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៧,០% ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និងដោយឈរលើមូលដ្ឋាននៃលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូល ជាពិសេស ចំណូលគយ និងចំណូលពន្ធដារឆ្នាំ ២០១៦ និងឆ្នាំ ២០១៧ នេះ, ក្របខ័ណ្ឌថវិកាឆ្នាំ ២០១៨ ត្រូវបានរៀបចំឡើង ក្រោមការកំណត់ដូចតទៅ៖

| សូចនាករថវិកា | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| **ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (% ផសស)** | **17.82** | **18.89** | **18.57** | **18.75** |
| - ចំណូលចរន្ត (% ផសស) | 17.66 | 18.74 | 18.40 | 18.57 |
| **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (% ផសស)** | **22.70** | **22.03** | **23.63** | **24.59** |
| - ចំណាយចរន្ត (% ផសស) | 14.68 | 14.28 | 15.42 | 16.09 |
| **អតិរេកចរន្ត (% ផសស)** | **2.98** | **4.46** | **2.98** | **2.48** |
| **ឱនភាពសរុប (% ផសស)** | **-4.87** | **-3.13** | **-5.07** | **-5.84** |

**ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ** ត្រូវបានគ្រោងចំនួន ១៨ ៥៨៧ ០០៣ លានរៀល ស្មើនឹង ១៨,៧៥% នៃ ផសស និងមានកំណើន ១១,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ចំណែកឯ **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ** ត្រូវបានគ្រោងចំនួន ២៤ ៣៧៥ ១០២ លានរៀល ស្មើនឹង ២៤,៥៩% នៃ ផសស និងមានកំណើន ១៥,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៧។ ជាលទ្ធផល **អតិរេកថវិកាចរន្ត** អាចរក្សាបានក្នុងកម្រិតប្រមាណ **២,៤៨%** នៃ ផសស នៅឆ្នាំ ២០១៨ និងមាន **ឱនភាពថវិកាសរុប** ស្មើនឹង **-៥,៨៤%** នៃ ផសស ស្របតាមគោលនយោបាយវិត្តារកម្មថវិកាប្រយ័ត្នប្រយែងរបស់រាជរដ្ឋាភិបាល។

## ៤.-គម្រោងចំណូល-ចំណាយថវិការដ្ឋ

### ៤.១-គម្រោងចំណូលថវិការដ្ឋ

| ចំណូលថវិកា (ឯកតាលានរៀល) | ២០១៧ | | ២០១៨ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណូលថវិការដ្ឋ ឬ ថវិកាជាតិ** | **21,151,985** | **23.63%** | **23,383,942** | **23.59%** | **10.6%** |
| • *ថ្នាក់ជាតិ* | 20,184,457 | 22.55% | 22,437,138 | 22.64% | 11.2% |
| • *ថ្នាក់ក្រោមជាតិ* | 967,528 | 1.08% | 946,804 | 0.96% | -2.1% |
| **១. ចំណូលចរន្តថវិការដ្ឋ** | **16,468,997** | **18.40%** | **18,406,810** | **18.57%** | **11.8%** |
| **ក. ចំណូលសារពើពន្ធថវិការដ្ឋ** | **14,135,400** | **15.79%** | **15,986,005** | **16.13%** | **13.1%** |
| - *ថ្នាក់ជាតិ* | 13,209,100 | 14.76% | 15,075,562 | 15.21% | 14.1% |
| - *ថ្នាក់ក្រោមជាតិ* | 926,300 | 1.03% | 910,443 | 0.92% | -1.7% |
| **ខ. ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ** | **2,333,597** | **2.61%** | **2,420,805** | **2.44%** | **3.7%** |
| - *ថ្នាក់ជាតិ* | 2,292,369 | 2.56% | 2,384,444 | 2.41% | 4.0% |
| - *ថ្នាក់ក្រោមជាតិ* | 41,228 | 0.05% | 36,361 | 0.04% | -11.8% |
| **២. ចំណូលមូលធនថវិការដ្ឋ** | **4,682,988** | **5.23%** | **4,977,132** | **5.02%** | **6.3%** |
| • *ក្នុងប្រទេស* | 148,431 | 0.17% | 180,193 | 0.18% | 21.4% |
| • *ក្រៅប្រទេស* | 4,534,557 | 5.07% | 4,796,939 | 4.84% | 5.8% |

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវ**បង្កើនចំណូលសរុបថវិការដ្ឋ ឬ ចំណូលសរុបថវិកាជាតិ** ឱ្យស្មើនឹង ២៣ ៣៨៣ ៩៤២ លានរៀល ក្នុងនោះ ចំណូលចរន្តថ្នាក់ជាតិឱ្យស្មើនឹង ១៧ ៤៦០ ០០៦ លានរៀល (ដែលរួមមាន ចំណូលសារពើពន្ធ ១៥ ០៧៥ ៥៦២ លានរៀល និង ចំណូលមិនមែនសារពើពន្ធ ២ ៣៨៤ ៤៤៤ លានរៀល)។ ដោយឡែក សម្រាប់ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៤ ៩៧៧ ១៣២ លានរៀល, ត្រូវជា ៥,០២% នៃ ផសស គឺមានកំណើន ៦,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៧។

ទន្ទឹមនេះ រាជរដ្ឋាភិបាលបានសម្រេចលុបកម្រៃគ្រប់គ្រងការនាំចេញ (Export Management Fee) ដែលមានថវិកាចំនួនប្រមាណ ៨២ ៥៤២ លានរៀល សមមូលនឹងប្រមាណជាង ២០ លានដុល្លារអាមេរិក ក្នុងគោលបំណង៖ (ទី១)-បង្កើនការទាក់ទាញនូវការវិនិយោគថ្មីៗបន្ថែមទៀតនៅកម្ពុជា ដើម្បីរួមចំណែកបន្តលើកស្ទួយកំណើនសេដ្ឋកិច្ច និងបង្កើតការងារកាន់តែច្រើនជូនពលករកម្ពុជា និង (**ទី២**)-ដើម្បីជួយសម្រួលដល់ម្ចាស់រោងចក្រ/សហគ្រាស ឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដំឡើងប្រាក់ឈ្នួលអប្បបរមា [ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង] ឱ្យបានដល់ ១៧០ ដុល្លារអាមេរិក នៅឆ្នាំ ២០១៨ ជូនកម្មករនិយោជិតម្នាក់ៗ។

## ៤.២-គម្រោងចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០១៨ **ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ** ត្រូវបានគ្រោងចំនួន **២៤ ៣៧៥ ១០២ លានរៀល** ត្រូវជា ២៤,៥៩% នៃ ផសស គឺមានកំណើន ១៥,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ដែលក្នុងនោះ (១)-**ចំណាយចរន្តថវិការដ្ឋមានចំនួន ១៥ ៩៤៥ ៤១៨ លានរៀល** ត្រូវជា ១៦,០៩% នៃ ផសស គឺមានកំណើន ១៥,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ និង (២)-**ចំណាយមូលធនថវិការដ្ឋមានចំនួន ៨ ៤២៩ ៦៨៤ លានរៀល** ត្រូវជា ៨,៥០% នៃ ផសស គឺមានកំណើន ១៤,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៧។

| ចំណាយថវិកា (ឯកតាលានរៀល) | ២០១៧ | | ២០១៨ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណាយថវិការដ្ឋ ឬ ថវិកាជាតិ** | **21,151,985** | **23.63%** | **24,375,102** | **24.59%** | **15.2%** |
| • *ថ្នាក់ជាតិ* | 20,184,457 | 22.55% | 23,428,298 | 23.64% | 16.1% |
| • *ថ្នាក់ក្រោមជាតិ* | 1,605,714 | 1.79% | 1,684,674 | 1.70% | 4.9% |
| **១. ចំណាយចរន្តថវិការដ្ឋ** | **13,799,079** | **15.42%** | **15,945,418** | **16.09%** | **15.6%** |
| ***១.១. ថ្នាក់ជាតិ*** | **13,050,686** | **14.58%** | **15,218,166** | **15.35%** | **16.6%** |
| *•បន្ទុកបុគ្គលិក* | 6,804,059 | 7.60% | 7,914,924 | 7.99% | 16.3% |
| *•ក្រៅបន្ទុកបុគ្គលិក* | 6,246,627 | 6.98% | 7,303,243 | 7.37% | 16.9% |
| ***១.២. ថ្នាក់ក្រោមជាតិ*** | **1,386,579** | **1.55%** | **1,465,122** | **1.48%** | **5.7%** |
| *•បន្ទុកបុគ្គលិក* | 330,329 | 0.37% | 388,044 | 0.39% | 17.5% |
| *•ក្រៅបន្ទុកបុគ្គលិក* | 1,056,250 | 1.18% | 1,077,078 | 1.09% | 2.0% |
| **២. ចំណាយមូលធនថវិការដ្ឋ** | **7,352,906** | **8.21%** | **8,429,684** | **8.50%** | **14.6%** |
| *- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 2,402,835 | 2.68% | 3,145,352 | 3.17% | 30.9% |
| *+ ក្នុងនោះចំណាយមូលធនថ្នាក់ក្រោមជាតិ* | *219,135* | *0.24%* | *219,552* | *0.22%* | *0.2%* |
| *- ការទូទាត់ប្រាក់ខ្ចី* | 665,514 | 0.74% | 737,393 | 0.74% | 10.8% |
| *- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 4,284,557 | 4.79% | 4,546,939 | 4.59% | 6.1% |

### ៤.២.១-ថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០១៨ មានទិសដៅជាយុទ្ធសាស្ត្រកំណត់**ចំណាយថវិកាថ្នាក់ជាតិ**ឱ្យស្ថិតក្នុងកម្រិតចំនួន ២៣ ៤២៨ ២៩៨ លានរៀល ត្រូវជា ២៣,៦៤% នៃ ផសស គឺមានកំណើន ១៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ដែលក្នុងនោះ **ចំណាយចរន្តថ្នាក់ជាតិ**មានចំនួន ១៥ ២១៨ ១៦៦ លានរៀល និង **ចំណាយមូលធនថ្នាក់ជាតិ**មានចំនួន ៨ ២១០ ១៣២ លានរៀល។

**ក. ចំណាយលើបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន ៧ ៩១៤ ៩២៤ លានរៀល សម្រាប់(១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ១២,០% តាមតម្លៃឯកតាសន្ទស្សន៍ ២ ១៣០ រៀល ដោយអនុវត្ត ចាប់ពីខែមករា ឆ្នាំ ២០១៨, (២)-ការដំឡើងប្រាក់បំណាច់មុខងារនឹងត្រូវអនុវត្តចាប់ពីខែមេសា ឆ្នាំ ២០១៨ តាមកម្រិតចន្លោះពី ៤០ ០០០ រៀល ទៅ ១០០ ០០០ រៀល, (៣)-ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាពី ៥០០ ០០០ រៀល ទៅដល់ ៦០០ ០០០ រៀល ដោយអនុវត្តចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ ២០១៨, (៤)-ការដំឡើងរបបសោធនប្រចាំខែទាបបំផុតពី ៤២០ ០០០ រៀល ទៅដល់ ៤៨០ ០០០ រៀល ជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងផ្តល់បន្ថែមចន្លោះពី ២០ ០០០ រៀល និង ៤០ ០០០ រៀល ជូនដល់និវត្តជនដោយផ្អែកលើកម្រិតរបបសោធនប្រចាំខែ ដោយគិតចាប់ពីខែមេសា ឆ្នាំ ២០១៨។

ជារួម នៅឆ្នាំ ២០១៨ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ នឹងត្រូវបានកើនឡើងជិត ៣ ដង ធៀបនឹង ឆ្នាំ ២០១៣ ដែលមានស្ថានភាពផ្លាស់ប្តូរដូចខាងក្រោម៖

- **បៀវត្សមន្ត្រីរាជការស៊ីវិល** នឹងត្រូវបានដំឡើងពីចំនួន ៨៥៣ ៥០០ រៀល នៅឆ្នាំ ២០១៧ ដល់ប្រមាណ ៩១៤ ៤៥០ រៀល នៅខែមករា ឆ្នាំ ២០១៨, ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ០១៤ ៤៥០** រៀល ចាប់ពីខែមេសា ឆ្នាំ ២០១៨, បើធៀបឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៣៤៤ ០០០ រៀល ប៉ុណ្ណោះ;
- **បៀវត្សគ្រូបង្រៀន និង គ្រូពេទ្យ** នឹងត្រូវបានដំឡើងពីចំនួន ៩៥៣ ៥០០ រៀល នៅឆ្នាំ ២០១៧ ដល់ប្រមាណ ១ ០១៤ ៤៥០ រៀល នៅខែមករា ឆ្នាំ ២០១៨ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ១១៤ ៤៥០** រៀល ចាប់ពីខែមេសា ឆ្នាំ ២០១៨, បើធៀបឆ្នាំ ២០១៣ បៀវត្សគ្រូបង្រៀនមានត្រឹម ៤០០ ០០០ រៀល និង បៀវត្សគ្រូពេទ្យមានត្រឹម ៣៦០ ០០០ រៀល ប៉ុណ្ណោះ;
- **បៀវត្សនគរបាល (ពលបាលត្រី)** នឹងត្រូវបានដំឡើងពីចំនួន ៩៣៧ ៩៧៧ រៀល (គិតបញ្ចូលទាំងរបបអង្ករ) នៅឆ្នាំ ២០១៧ ដល់ប្រមាណ ៩៩៨ ៩២៧ រៀល (គិតបញ្ចូលទាំងរបបអង្ករ) នៅខែមករា ឆ្នាំ ២០១៨ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ០៩៨ ៩២៧** រៀល (គិតបញ្ចូលទាំងរបបអង្ករ) ចាប់ពីខែមេសា ឆ្នាំ ២០១៨, បើធៀបឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៣៨០ ០០០ រៀល ប៉ុណ្ណោះ;
- **បៀវត្សយោធិន (ពលទោ)** នឹងត្រូវបានដំឡើងពីចំនួន ៨២២ ៥០០ រៀល (មិនគិតបញ្ចូលរបបអង្ករ) នៅឆ្នាំ ២០១៧ ដល់ប្រមាណ ៨៧៦ ៥៥០ រៀល (មិនគិតបញ្ចូលរបបអង្ករ) នៅខែមករា ឆ្នាំ ២០១៨ ហើយនឹងត្រូវបានដំឡើងដល់ ៩៧៦ ៥៥០ រៀល ចាប់ពីខែមេសា ឆ្នាំ ២០១៨ បើគិតបញ្ចូលរបបអង្ករ ត្រូវជាប្រមាណ **១ ០៣៥ ០២៧** រៀល, បើធៀបឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៣១៦ ០០០ រៀល ប៉ុណ្ណោះ។

ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានកែសម្រួលនូវកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធលើប្រាក់បៀវត្ស ដើម្បីអនុគ្រោះដល់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្ស ១ ២០០ ០០០ រៀល ឬ តិចជាង ឱ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធជាង ១ លានរៀល រាជរដ្ឋាភិបាលក៏បាន**គ្រោងថវិកាចំនួន ៣០ ០០០ លានរៀល សម្រាប់រៀបចំជាមូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន**។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ និងដំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួន ២ ទៀត ដោយអនុវត្តចាប់ពីខែមករា ឆ្នាំ ២០១៨ ដែលរួមមាន៖

- **ផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី** ដោយបង្កើនពី ៦០០ ០០០ រៀលទៅចំនួន ៨០០ ០០០ រៀល សម្រាប់ការសម្រាលបានកូនមួយ និងចំនួន ១ ៦០០ ០០០០ រៀល សម្រាប់ការសម្រាលបានកូនភ្លោះពីរ និងចំនួន ២ ៤០០ ០០០ រៀល សម្រាប់ការសម្រាលបានកូនភ្លោះបី
- **ផ្តល់ប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព** ដោយក្នុងម្នាក់ៗ ត្រូវបានដំឡើងពីចំនួន ១ ២០០ ០០០ រៀល ទៅ ២ ០០០ ០០០ រៀល ចំពោះមរណភាពដោយជម្ងឺធម្មតា និងដំឡើងពីចំនួន ១ ៥០០ ០០០ រៀល ទៅ ៤ ០០០ ០០០ រៀល ចំពោះមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ។

**ខ. <u>ចំណាយមិនមែនបន្ទុកបុគ្គលិក</u>** ត្រូវបានគ្រោងចំនួន ៧ ៣០៣ ២៤៣ លានរៀល, មានសមាមាត្រស្មើនឹង ៤៨,០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៣៧% នៃ ផសស គឺមានកំណើន ១៦,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៧, ហើយត្រូវបានវិភាជដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ដូចខាងក្រោម៖

**<u>វិស័យរដ្ឋបាលទូទៅ</u>**

- គាំទ្រការកែទម្រង់ការបោះឆ្នោត
- លើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- គាំទ្រកំណែទម្រង់វិស័យដីធ្លី
- គាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម
- គាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- បង្កើនប្រសិទ្ធភាពនៃកិច្ចការទូត តាមរយៈបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មន្ត្រីការទូត។

**<u>វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់</u>**

- គាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកម្លាំងប្រដាប់អាវុធ
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខមាលភាពកងកម្លាំងប្រដាប់អាវុធ
- បង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ

- គាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ
- គាំទ្រការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព
- គាំទ្រដល់ប្រតិបត្តិការផលិតអត្តសញ្ញាណប័ណ្ណ
- ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ
- ប្រយុទ្ធប្រឆាំងគ្រឿងញៀន
- គាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

**វិស័យសង្គមកិច្ច**

- ពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ
- អភិវឌ្ឍជំនាញ និងវិស័យការងារ
- លើកកម្ពស់គុណភាពសេវាសុខាភិបាល
- ទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ
- ឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន និងបង្កើនថវិកាគាំទ្រដល់ការបង្កើតសមាគមមនុស្សចាស់នៅតាមឃុំសង្កាត់ចំនួន ១ ២៤២ នៅទូទាំងប្រទេស
- បង្កើនការឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី ខេត្ត និងការឧបត្ថម្ភគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា ដើម្បីផ្តល់សេវាជូនជនពិការ
- ផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រនៅតាមសហគម ក្នុងជំហានសាកល្បង
- ការពារ និងអភិរក្សធនធានធម្មជាតិ
- អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ
- សុខដុមនីយកម្មសាសនា។

**វិស័យសេដ្ឋកិច្ច**

- បន្តការលើកកម្ពស់បច្ចេកទេសកសិកម្ម
- ជំរុញផលិតកម្មស្បៀង ពិសេសការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម
- ពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល
- បង្កើនការគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ
- រៀបចំផែនការមេនៃការអភិវឌ្ឍប្រព័ន្ធឡជីស្ទីក
- ជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ
- ជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា
- បណ្តុះបណ្តាលធនធានមនុស្ស
- បន្តជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត
- ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ
- អភិវឌ្ឍប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច

- ពង្រឹងនូវក្របខ័ណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
- អភិវឌ្ឍប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

លើសពីនេះ ចំណុចលេចធ្លោរបស់ថវិកាឆ្នាំ ២០១៨ ស្របតាមកម្មវិធីថ្មីៗរបស់រាជរដ្ឋាភិបាលមានជាអាទិ៍ ដូចជា៖

- **ការថែទាំសុខភាពសម្រាប់កម្មករ៖** បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ទទួលបានរបបថែទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ
- **ការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត៖** បានគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់បើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនីនៅក្រោយពេលសម្រាលកូន និងសម្រាកលំហែមាតុភាព ដោយផ្តល់ថវិកា ៤០០ ០០០ រៀល សម្រាប់ការសម្រាលបានកូនមួយ, សម្រាលបានកូនភ្លោះពីរទទួលបានថវិកា ៨០០ ០០០ រៀល និងសម្រាលបានកូនភ្លោះបី ទទួលបានថវិកា ១ ២០០ ០០០ រៀល
- **ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា៖** បានគ្រោងថវិកានៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ជា**មូលនិធិទ្រទ្រង់និរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា** បន្ថែមលើឥណទានថវិកាដែលត្រូវផ្តល់ជូនមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីធានាថា មន្ទីរពេទ្យនេះនៅតែអាចរក្សាបាននូវស្តង់ដាគុណភាព និងការផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃដដែល នៅពេលមានការផ្ទេរការគ្រប់គ្រងពីលោក Beat Richner ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលវិញ
- **ការបន្តសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការចុះសួរសុខទុក្ខកម្មករ-កម្មការិនី** តាមបណ្តារោងចក្រសហគ្រាស ដើម្បីស្វែងយល់និងរកដំណោះស្រាយសមស្របជូនកម្មករ-កម្មការិនី ក៏ដូចជាជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

**គ. <u>ចំណាយមូលធនថ្នាក់ជាតិ</u>** ត្រូវបានគ្រោងចំនួន ៨ ២១០ ១៣២ លានរៀល មានសមាមាត្រស្មើនឹង ៣៥,០% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា ៨,២៨% នៃ ផសស គឺមានកំណើន ១៥,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៧។ ចំណាយនេះមានគោលដៅផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធីក្នុងវិស័យអាទិភាពដោយផ្តោតទៅលើការទ្រទ្រង់កំណើនសេដ្ឋកិច្ច ការលើកកម្ពស់ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ដូចជា៖

- ការកសាង និងជួសជុលផ្លូវថ្នល់ ព្រមទាំងការបន្តស្តារផ្លូវដែកទិសខាងជើង និងកសាងកំពង់ផែទន្លេ
- ការបន្តស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ពិសេសលើកកម្ពស់ការគ្រប់គ្រង និងទប់ទល់នឹងទឹកជំនន់
- ការបន្តសាងសង់ និង ជួសជុលសាលារៀននៅតាមបណ្តាខេត្ត
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, វិស័យគមនាគមន៍ និងដឹកជញ្ជូន និងវិស័យអាទិភាពផ្សេងៗទៀត ដូចជា សុខាភិបាល និងការផ្គត់ផ្គង់ទឹកស្អាត ជាដើម
- ការបន្តអនុវត្តសាកល្បងនូវកម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work) ដែលជាអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាលក្នុងការបង្កើតការងារនៅទីជនបទ
- ការបន្តវិនិយោគលើវិស័យអគ្គិសនី ដើម្បីបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះថ្លៃអគ្គិសនីនៅជនបទ

- ការផ្តល់ថវិកាគម្រោងវិនិយោគផ្ទាល់ក្នុងខេត្តត្បូងឃ្មុំ
- ការបន្តវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្ម និងការវិនិយោគលើការជំរុញផលិតកម្មស្បៀង ជាពិសេសការផលិតស្រូវ និងបន្លែ
- ការបន្តផ្តល់ឥណទានដល់វិស័យស្រូវអង្ករ ជាពិសេសផ្តល់អាទិភាពលើការវិនិយោគសាងសង់ឡសម្ងួត និងឃ្លាំងស្តុកស្រូវអង្ករ, និងជំរុញស្ថិរភាពភាវូបនីយកម្មថ្លៃស្រូវ និងការទិញស្រូវក្នុងស្រុក។

ជាលទ្ធផលរួម ថវិកាថ្នាក់ជាតិត្រូវបានបែងចែកទៅតាមវិស័យទាំង ៤ ដូចខាងក្រោម៖

| **ចំណាយថវិកាតាមវិស័យ** (ឯកតាលានរៀល) | **២០១៧** | | **២០១៨** | | **% កំណើន** |
|---|---|---|---|---|---|
| | **ច្បាប់** | **% ផសស** | **គ្រោង** | **% ផសស** | |
| ***១. វិស័យរដ្ឋបាលទូទៅ*** | **2,156,626** | **2.41%** | **2,453,008** | **2.47%** | **13.7%** |
| ***ក. ចំណាយចរន្ត*** | **1,986,942** | **2.22%** | **2,263,304** | **2.28%** | **13.9%** |
| *-បន្ទុកបុគ្គលិក* | 515,991 | 0.58% | 626,302 | 0.63% | 21.4% |
| *-ក្រៅបន្ទុកបុគ្គលិក* | 1,470,951 | 1.64% | 1,637,002 | 1.65% | 11.3% |
| ***ខ. ចំណាយមូលធន*** | **169,684** | **0.19%** | **189,704** | **0.19%** | **11.8%** |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 12,000 | 0.01% | 16,500 | 0.02% | 37.5% |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 157,684 | 0.18% | 173,204 | 0.17% | 9.8% |
| ***២. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់*** | **3,441,522** | **3.84%** | **4,005,665** | **4.04%** | **16.4%** |
| ***ក. ចំណាយចរន្ត*** | **3,338,400** | **3.73%** | **3,894,376** | **3.93%** | **16.7%** |
| *-បន្ទុកបុគ្គលិក* | 2,598,636 | 2.90% | 3,063,664 | 3.09% | 17.9% |
| *-ក្រៅបន្ទុកបុគ្គលិក* | 739,764 | 0.83% | 830,712 | 0.84% | 12.3% |
| ***ខ. ចំណាយមូលធន*** | **103,122** | **0.12%** | **111,289** | **0.11%** | **7.9%** |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 54,100 | 0.06% | 54,600 | 0.06% | 0.9% |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 49,022 | 0.05% | 56,689 | 0.06% | 15.6% |
| ***៣. វិស័យសង្គមកិច្ច*** | **5,754,093** | **6.43%** | **7,014,100** | **7.08%** | **21.9%** |
| ***ក. ចំណាយចរន្ត*** | **4,836,498** | **5.40%** | **5,658,959** | **5.71%** | **17.0%** |
| *-បន្ទុកបុគ្គលិក* | 3,269,859 | 3.65% | 3,765,808 | 3.80% | 15.2% |
| *-ក្រៅបន្ទុកបុគ្គលិក* | 1,566,639 | 1.75% | 1,893,151 | 1.91% | 20.8% |
| ***ខ. ចំណាយមូលធន*** | **917,595** | **1.03%** | **1,355,140** | **1.37%** | **47.7%** |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 90,000 | 0.10% | 420,000 | 0.42% | 366.7% |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 827,595 | 0.92% | 935,140 | 0.94% | 13.0% |
| ***៤. វិស័យសេដ្ឋកិច្ច*** | **5,396,622** | **6.03%** | **5,666,091** | **5.72%** | **5.0%** |
| ***ក. ចំណាយចរន្ត*** | **1,306,367** | **1.46%** | **1,379,185** | **1.39%** | **5.6%** |
| *-បន្ទុកបុគ្គលិក* | 419,572 | 0.47% | 459,150 | 0.46% | 9.4% |
| *-ក្រៅបន្ទុកបុគ្គលិក* | 886,795 | 0.99% | 920,035 | 0.93% | 3.7% |
| ***ខ. ចំណាយមូលធន*** | **4,090,255** | **4.57%** | **4,286,907** | **4.33%** | **4.8%** |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 840,000 | 0.94% | 905,000 | 0.91% | 7.7% |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 3,250,255 | 3.63% | 3,381,907 | 3.41% | 4.1% |

១២

## ចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន សម្រាប់ឆ្នាំ ២០១៣-២០១៨
## (ចំណាយចរន្ត និង ចំណាយមូលធន)




## ទំហំកំណើនចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន
## សម្រាប់ឆ្នាំ ២០១៨ ធៀបនឹងឆ្នាំ ២០១៣



## ៤.២.២-ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

| ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ឯកតាលានរៀល) | ២០១៧ | | ២០១៨ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ | 967,528 | 1.08% | 946,804 | 0.96% | -2.1% |
| • ចំណូលសារពើពន្ធ | 926,300 | 1.03% | 910,443 | 0.92% | -1.7% |
| • ចំណូលមិនមែនសារពើពន្ធ | 41,228 | 0.05% | 36,361 | 0.04% | -11.8% |
| សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ | 1,605,714 | 1.79% | 1,684,674 | 1.70% | 4.9% |
| • ចំណាយចរន្ត | 1,386,579 | 1.55% | 1,465,122 | 1.48% | 5.7% |
| • ចំណាយមូលធន | 219,135 | 0.24% | 219,552 | 0.22% | 0.2% |
| ឱនភាពថវិកា | -638,186 | -0.71% | -737,870 | -0.74% | 15.6% |
| ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ | 638,186 | 0.71% | 737,870 | 0.74% | 15.6% |
| • រាជធានី-ខេត្ត | 128,710 | 0.14% | 148,814 | 0.15% | 15.6% |
| • មូលនិធិក្រុង-ស្រុក | 134,073 | 0.15% | 155,015 | 0.16% | 15.6% |
| • មូលនិធិឃុំ-សង្កាត់ | 375,403 | 0.42% | 434,041 | 0.44% | 15.6% |

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត មូលនិធិក្រុង-ស្រុក និង មូលនិធិឃុំ-សង្កាត់ មានឱនភាពថវិកាចំនួន ៧៣៧ ៨៧០ លានរៀល ដែលត្រូវបានឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ហើយការឧបត្ថម្ភនេះមានកំណើន ១៥,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ត្រូវជា ០,៧៤% នៃ ផសស ។

ជាមួយនឹងការបង្កើនចំណាយដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ, អាទិភាពចំណាយត្រូវបានផ្តល់ដល់ការដំឡើងប្រាក់បៀវត្សជូនដល់ក្រុមប្រឹក្សារាជធានី ខេត្ត, ក្រុង ស្រុក ខណ្ឌ, ឃុំ សង្កាត់ និង មន្ត្រីភូមិ ផងដែរ។

## ៤.២.៣-ស្ថានភាពបំណុល

ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលតែងតែប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន ០៤ ដូចខាងក្រោម៖

(១). ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

(២). ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

(៣). ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម

(៤). ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

រាជរដ្ឋាភិបាលកំណត់ពិដានក្នុងការខ្ចីសម្រាប់ឆ្នាំ ២០១៨ ក្នុងកម្រិត ១ ០០០ លានអេសដេអែរ ស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ក្នុងគោលដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការឥណទានយ៉ាងគំហុក និងមានទំហំកាន់តែធំឡើងៗ សម្រាប់ធ្វើហិរញ្ញប្បទានគម្រោងវិនិយោគ-សាធារណៈដែលចេះតែរំកិលពីឆ្នាំមុនៗមក និងត្រូវរង់ចាំចុះហត្ថលេខារហូតដល់ជាង ១ ៨៩៣ លាន

អេសដេអ៊ែរ ក្នុងវិស័យអាទិភាពតែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង ជាពិសេសការសម្រេចឱ្យបាននូវគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងតិច ១% ក្នុងមួយឆ្នាំ។ កំណើននៃសេចក្តីត្រូវការឥណទានសម្បទាននេះ គឺមួយផ្នែកធំបណ្តាលមកពីនិន្នាការកាន់តែច្រើនរបស់ដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់នូវកម្ចីឥណទានសម្បទាន ជំនួសឱ្យហិរញ្ញប្បទានឥតសំណងដែលខ្លួនធ្លាប់ផ្តល់កន្លងមក ដោយសារការរីកចម្រើនលូតលាស់នៃសេដ្ឋកិច្ចក្នុងខណៈដែលកម្ពុជាកាន់តែមានសេចក្តីត្រូវការនៅក្នុងវិនិយោគសាធារណៈកាន់តែច្រើនថែមទៀត ស្របទៅតាមការរីកចម្រើនឡើងនៃសេដ្ឋកិច្ចរបស់ខ្លួន។ ជារួម ការបង្កើនទំហំនៃការខ្ចីនេះ នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌកដល់កម្ពុជាទេ ព្រោះថានៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើន នោះសមត្ថភាពសងរបស់កម្ពុជាក៏ខ្ពស់ជាងមុនដែរ។ ជាក់ស្តែង បើផ្អែកទៅលើលទ្ធផលនៃការវិភាគចីរភាពបំណុល ដោយឈរលើមូលដ្ឋានសន្មតិនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ ២០១៨ ក្នុងកម្រិត ១ ០០០ លានអេសដេអ៊ែរ គឺបានបង្ហាញថា អនុបាតបំណុលគន្លឹះទាំង ៥ របស់កម្ពុជាសុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។ ដូចនេះ ផ្អែកតាមបទដ្ឋានបច្ចេកទេសអន្តរជាតិគឺកម្ពុជាអាចបង្កើនពិដាននៃការខ្ចីថ្មីរហូតដល់ ១ ០០០ លានអេសដេអ៊ែរបាននៅឆ្នាំ ២០១៨ ដោយមិនមានការប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈឡើយ ពោលគឺស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានៅតែមាន **ចីរភាព** និង **ហានិភ័យកម្រិតទាប**នៅក្នុងរយៈពេលមធ្យមដដែល។ ម្យ៉ាងវិញទៀត ការបង្កើនពិដាននៃការខ្ចីនេះ គឺគ្រាន់តែជាការបំពេញនូវលក្ខខណ្ឌនីត្យានុកូលភាពក្នុងការខ្ចីប៉ុណ្ណោះ ក្នុងខណៈដែលការចុះហត្ថលេខាខ្ចីប្រាក់ជាក់ស្តែងអាចទាបជាងនេះដូចការអនុវត្តនៅបណ្តាឆ្នាំកន្លងទៅ។ ដោយឡែក ចំពោះការដកសាច់ប្រាក់សម្រាប់គម្រោងនីមួយៗវិញ គឺមានរយៈពេលជាមធ្យមប្រមាណពី ៣ ឆ្នាំ ទៅ ៥ ឆ្នាំឯណោះ។

ក្នុងន័យនេះ ការកំណត់ពិដានក្នុងការខ្ចីសម្រាប់ឆ្នាំ ២០១៨ ក្នុងកម្រិត ១ ០០០ លានអេសដេអ៊ែរ គឺដើម្បីឱ្យរាជរដ្ឋាភិបាលអាចចុះហត្ថលេខាខ្ចីប្រាក់ពីគេបានក្នុងកម្រិត ១ ០០០ លានអេសដេអ៊ែរ **នៅក្នុងចំណោមគម្រោងសរុបចំនួន ២៦ ដែលមានលក្ខណៈសម្បត្តិរួចរាល់លើបេក្ខភាពគម្រោងដែលត្រូវរង់ចាំចុះហត្ថលេខាសរុបចំនួន ៣១ គម្រោង ដែលមានទឹកប្រាក់សរុបសមមូលនឹង ១ ៨៩៣ លានអេសដេអ៊ែរ** ដែលរួមមាន៖ ធនាគារពិភពលោកចំនួន ៤ គម្រោង ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ១០ គម្រោង សាធារណរដ្ឋប្រជាមានិតចិនចំនួន ៤ គម្រោង ប្រទេសជប៉ុនចំនួន ២ គម្រោង សាធារណរដ្ឋកូរ៉េចំនួន ២ គម្រោង សាធារណរដ្ឋបារាំងចំនួន ២ គម្រោង និងសាធារណរដ្ឋឥណ្ឌាចំនួន ២ គម្រោង **ក្នុងគោលដៅទ្រទ្រង់កំណើនសេដ្ឋកិច្ច ការលើកកម្ពស់ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ដែលរួមមាន៖**

- **វិស័យថាមពល៖** គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ជំហានទី ២ គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញជំហានទី ២ ដំណាក់កាលទី ២ កម្មវិធីថាមពលដើរដោយពន្លឺព្រះអាទិត្យសម្រាប់ការតភ្ជាប់ជាមួយថាមពលអគ្គិសនី គម្រោងសាងសង់ខ្សែបណ្តាញថាមពលអគ្គិសនីតង់ស្យុង ១១៥ គីឡូវ៉ុល ក្នុងគោលដៅពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះតម្លៃអគ្គិសនីនៅជនបទ ដើម្បីរួមចំណែកកាត់បន្ថយចំណាយរបស់ប្រជាជននៅជនបទផង និងកាត់បន្ថយថ្លៃដើមផលិតកម្មក្នុងវិស័យកសិកម្ម និងសិប្បកម្ម/ឧស្សាហកម្មជនបទផង
- **វិស័យធារាសាស្ត្រ៖** គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្វាហាប់ខេត្តកំពង់ស្ពឺ គម្រោងអភិវឌ្ឍន៍អាងទឹករក្សាខេត្តព្រះវិហារ គម្រោងអភិវឌ្ឍន៍វិស័យធារាសាស្ត្រនិងកសិកម្មដំណាក់កាលទី ២

- **វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** គម្រោងកែលម្អផ្លូវជាតិលេខ៣ លេខ៤ លេខ៥ គម្រោងអភិវឌ្ឍន៍ផ្លូវពីសំឡូត វាលវែង ទៅដល់កោះកុង គម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងទី ៣ ពីផ្លូវជាតិលេខ៥ ទៅផ្លូវជាតិលេខ១ និងគម្រោងកែលម្អការថែទាំផ្លូវ។ល។ និង
- **វិស័យអាទិភាពផ្សេងទៀត៖** គម្រោងក្នុងវិស័យកសិកម្ម សុខាភិបាល ទេសចរណ៍ ការផ្គត់ផ្គង់ទឹកស្អាត និងអប់រំ។

## សន្និធិបំណុលសាធារណៈក្រៅប្រទេស គិតត្រឹមដំណាច់ ខែមិថុនា ឆ្នាំ ២០១៧




## អនុបាតបំណុលគន្លឹះទាំង ៥



## ៥- សេចក្តីសន្និដ្ឋាន

ការរៀបចំថវិកាឆ្នាំ ២០១៨ ទោះបីជាជួបប្រទះនឹងបញ្ហាប្រឈម និងហានិភ័យមួយចំនួនក្តី ក៏បញ្ហាទាំងអស់ត្រូវបានដោះស្រាយ ហើយថវិកាត្រូវបានវិភាជន៍សម្រាប់អាទិភាពគោលនយោបាយសំខាន់ៗជាសារវន្ត។ ក្នុងន័យនេះ ថវិកាឆ្នាំ ២០១៨ អាចត្រូវបានសន្និដ្ឋានថាជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការជួយឱ្យរាជរដ្ឋាភិបាលអាចឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន និងអាចសម្រេចបុព្វហេតុចម្បងៗរបស់ខ្លួន ជាពិសេស ការបង្កើនល្បឿននៃការអភិវឌ្ឍ, ការលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងការចូលរួមដោះស្រាយបញ្ហាជាច្រើនទៀតរបស់ជាតិ និងប្រជាជន ដែលស្តែងឡើងតាមរយៈការបន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការទូទៅឱ្យដល់គោលដៅជាង ១ លានរៀល ក្នុងឆ្នាំ ២០១៨ និង ការបង្កើនការផ្តល់នូវមធ្យោបាយ និង ធនធានសមស្របដល់ក្រសួង-ស្ថាប័ន ដើម្បីបំពេញភារកិច្ចរបស់ខ្លួនស្របតាមទិសដៅនៃការកែទម្រង់ស៊ីជម្រៅឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងបន្តគាំទ្រការវិនិយោគចាំបាច់នានាដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច។

សរុបមក ថវិកាឆ្នាំ ២០១៨ អាចប្រសិទ្ធនាមបានថាជា **"ថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខាងតែបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោក ដែលកាន់តែមានសភាពស្មុគស្មាញ ដើម្បីបន្តរក្សាសន្តិភាព ស្ថេរភាព ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាពតទៅមុខឥតឈប់ឈរក្នុងនីតិកាលបន្តបន្ទាប់ទៀត"**។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**